ក្រសួងមហាផ្ទៃ / Ministry of Interior

អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យឧត្តមស្នងការ

# ព្រឹត្តបត្រព័ត៌មាន

## លក្ខខណ្ឌតម្រូវជាមូលដ្ឋានមួយចំនួននៃនីតិវិធីរៀបចំការធ្វើបាតុកម្ម ស្របតាមច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធី និងគោលការណ៍ណែនាំសម្រាប់អនុវត្តច្បាប់នេះ។

### ១). កាតព្វកិច្ចរបស់អ្នករៀបចំ

ប្រសិនបើអ្នករៀបចំធ្វើការប្រមូលផ្តុំនៅទីលានសាធារណៈណាមួយ ឬការដើរដង្ហែជាក្បួន នៅតាមផ្លូវសាធារណៈ ដើម្បីទាមទារអ្វីមួយ

↓

អ្នកត្រូវដាក់លិខិតជូនដំណឹងជាលាយលក្ខអក្សរនៅសាលា រាជធានីភ្នំពេញ ឬនៅសាលាខេត្ត ដោយបញ្ជាក់អំពី ៖

- នាម និងគោត្តនាមរបស់អ្នកដឹកនាំ ៣ រូប
- អាស័យដ្ឋានរបស់អ្នកដឹកនាំ ៣ រូប
- អត្តសញ្ញាណប័ណ្ណថតចម្លងរបស់អ្នកដឹកនាំ ៣ រូប
- គោលបំណងនៃការធ្វើបាតុកម្មនោះ
- កាលបរិច្ឆេទ ពេលវេលា និងរយៈពេលធ្វើបាតុកម្ម
- ទីតាំង និងវិថី/ផ្លូវដែលត្រូវប្រើប្រាស់សម្រាប់ធ្វើបាតុកម្ម
- ចំនួនអ្នកចូលរួម និង
- ចំនួនយានជំនិះតាមប្រភេទនីមួយៗ

↓

ពេលត្រូវដាក់លិខិត ៖ យ៉ាងហោចណាស់ ៥ថ្ងៃ នៃថ្ងៃធ្វើការ មុននឹងធ្វើការប្រមូលផ្តុំ ឬការដើរដង្ហែរក្បួន

---

ប្រសិនបើអ្នករៀបចំធ្វើការប្រមូលផ្តុំនៅកន្លែងបញ្ចេញមតិសាធារណៈ ឬនៅទីតាំងឯកជន ឬនៅទីតាំងសម្ធហភាពណាមួយ ដើម្បីធ្វើការទាមទារអ្វីមួយ

↓

អ្នកត្រូវដាក់លិខិតជូនដំណឹងជាលាយលក្ខអក្សរ ដោយបញ្ជាក់អំពី៖

- នាម និងគោត្តនាមរបស់អ្នកដឹកនាំ ៣ រូប
- អត្តសញ្ញាណប័ណ្ណថតចម្លងរបស់អ្នកដឹកនាំទាំង ៣ រូប នោះ
- ហត្ថលេខា ឬស្នាមមេដៃរបស់អ្នកដឹកនាំ ៣ រូប
- ចំពោះទីតាំងឯកជន ឬទីតាំងសម្ធហភាពត្រូវមានការយល់ព្រមពីម្ចាស់ទ្រព្យ ឬពីគណៈគ្រប់គ្រងទ្រព្យ

↓

ពេលត្រូវដាក់លិខិត ៖ យ៉ាងតិច ១២ ម៉ោងជាមុន ក្នុងថ្ងៃធ្វើការ ឬ ៣៦ ម៉ោងជាមុន ក្នុងថ្ងៃឈប់សម្រាកជាសាធារណៈ

---

លិខិតជូនដំណឹងជាលាយលក្ខអក្សរ ត្រូវដាក់នៅសាលារាជធានី ឬសាលាខេត្ត

---

ការប្រមូលផ្តុំ ដែលមិនចាំបាច់តម្រូវឲ្យមានលិខិតជូនដំណឹងជាលាយលក្ខអក្សរទៅកាន់អាជ្ញាធរ

↓

ការប្រមូលផ្តុំ មិនទាក់ទងទៅនឹងការទាមទារជាសាធារណៈ ណាមួយ ដូចជា ៖

- ជួបជុំគ្នា ក្នុងគោលបំណងដទៃផ្សេងក្រៅពីការតវ៉ាទាមទារជាសាធារណៈ
- ការជួបប្រជុំ ដើម្បីពិភាក្សា និងស្វែងរកដំណោះស្រាយបញ្ហាជាក់លាក់ណាមួយ
- សកម្មភាពផ្សព្វផ្សាយអប់រំផ្សេងៗ ដូចជា ៖
  - ការបណ្តុះបណ្តាល
  - សិក្ខាសាលា
  - វេទិកាសាធារណៈ
  - សន្និសីទសារព័ត៌មាន ។ល។
- ការធ្វើព្យុហយាត្រា ឬពិធីដង្ហែសព
- ការជួបប្រជុំអំឡុងពេលយុទ្ធនាការបោះឆ្នោត
- ឬការធ្វើកិច្ចការសាសនា សិល្បៈ វប្បធម៌ ប្រពៃណី និង ទំនៀមទំលាប់ជាតិ

## ២). <u>កាតព្វកិច្ចរបស់អាជ្ញាធររាជធានី ឬខេត្ត</u>

នៅពេលទទួលលិខិតជូនដំណឹងអាជ្ញាធររាជធានី ឬខេត្ត ត្រូវ៖

- ចេញបង្កាន់ដៃទទួលស្គាល់ជាលាយលក្ខអក្សរជូនអ្នក ដែលបានដាក់លិខិតជូនដំណឹង
- ផ្សព្វផ្សាយលិខិតជូនដំណឹងនោះជាបន្ទាន់នៅទីកន្លែងណាមួយ ដែលងាយមើលឃើញក្នុងអាគាររដ្ឋបាល ឬនៅលើគេហទំព័រផ្លូវការរបស់ខ្លួន
- បញ្ជូនច្បាប់ថតចម្លងនៃលិខិតជូនដំណឹងនេះទៅកាន់ស្នាក់ការនគរបាលមូលដ្ឋាន ស្នាក់ការកងរាជអាវុធហត្ថ និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធដទៃទៀត។

ឆ្លើយតប ជាវិជ្ជមាន លើកលែងតែ ៖

- បាតុកម្មត្រូវចំលើថ្ងៃប្រារព្វពិធីបុណ្យធំៗ ដូចមានចែងក្នុងមាត្រា ៩ នៃច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធី

មានព័ត៌មានច្បាស់ថា ៖ បាតុកម្មអាចបង្កឲ្យមានគ្រោះថ្នាក់ ឬអាចបង្កឲ្យអន្តរាយដល់សន្តិសុខ សុវត្ថិភាព និង សណ្តាប់ធ្នាប់សាធារណៈ។ អាជ្ញាធររាជធានី ឬខេត្ត ត្រូវពិចារណាឲ្យបានហ្មត់ចត់ផងថា ៖

- *បាតុកម្មតវ៉ាមិនមែនសុទ្ធតែជា **"ការបង្កគ្រោះថ្នាក់ ឬប៉ះពាល់ធ្ងន់ធ្ងរដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ"** ទេ។*
- *ការកកស្ទះចរាចរណ៍ មិនមែនសុទ្ធតែជាការ **"បង្កគ្រោះថ្នាក់ ឬប៉ះ ពាល់ធ្ងន់ធ្ងរដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ"** ទេ។*

ធ្វើការឆ្លើយតបក្នុងកំឡុងពេល ៣ ថ្ងៃ នៃថ្ងៃធ្វើការ

- អាជ្ញាធររាជធានី ឬខេត្ត ត្រូវអញ្ជើញ អ្នកជូនដំណឹងមកពិភាក្សារកដំណោះស្រាយជាមួយគ្នា
- អាជ្ញាធររាជធានី ឬខេត្តត្រូវ ស្នើសុំយោបល់សម្រេចពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវឆ្លើយតបជាលាយលក្ខអក្សររយៈពេល ២៤ម៉ោង មុនពេលកំណត់ធ្វើបាតុកម្ម

ការមិនបានឆ្លើយតបពីអាជ្ញាធរ មានន័យថា អាជ្ញាធរបានយល់ ព្រម ហើយការធ្វើបាតុកម្មអាចប្រព្រឹត្តទៅបានដោយមិនមានការបំបែក ឬការរារាំងឡើយ។